ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៥ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

# សារាចរណែនាំ

# ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៣

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ដើម្បីឲ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងសម្រេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដូចតទៅ ៖

## ក.អំពីការធ្វើប្រតិភូកម្មថវិកានិងអាណាប័កផ្ទេរសិទ្ធិ

ក្រោយពេលទទួលបានសេចក្តីប្រកាសប្រគល់ថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

១. អភិបាលនៃគណៈអភិបាលរាជធានី ត្រូវចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឲ្យអភិបាលនៃគណៈអភិបាល ខណ្ឌនីមួយៗនិងចៅសង្កាត់នីមួយៗចំណុះរាជធានី ដើម្បីអនុវត្តថវិកាដោយខ្លួនឯង ដោយផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ច្បាប់ និងរតនាគាររាជធានី ខេត្ត ០១ច្បាប់ (ច្បាប់ដើម)។

២. អភិបាលនៃគណៈអភិបាលក្រុង ត្រូវចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មថវិកានិងអាណាប័កផ្ទេរសិទ្ធិទៅឲ្យចៅសង្កាត់នីមួយៗចំណុះក្រុងនីមួយៗ ដើម្បីអនុវត្តថវិកាដោយខ្លួនឯង ដោយផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ច្បាប់ និងរតនាគាររាជធានី ខេត្ត ០១ច្បាប់ (ច្បាប់ដើម) ។

៣. អភិបាលនៃគណៈអភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះថវិកាធ្វើប្រតិភូកម្មដែលអនុវត្តដោយអាណាប័កផ្ទេរសិទ្ធិ។

ក្រុមការងារគាំទ្រការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលមានប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន ប្រធានរតនាគារជាអនុប្រធាន និងនាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ជាសមាជិក ត្រូវបន្តជួយគាំទ្រដល់ការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ឲ្យសម្រេចបានដោយប្រសិទ្ធភាព ក្នុងករណីជួបបញ្ហាប្រឈមអ្វី ត្រូវរាយការណ៍សុំយោបល់ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន)។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## ខ.អំពីចំណូល

ឆ្នាំ២០១៣នេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ(ខណ្ឌជាថវិកាផ្នែករបស់រាជធានី)ជាថ្នាក់ថវិកាមួយ ដូចនេះ ដើម្បីអនុវត្តចំណូលមានប្រសិទ្ធភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការតែងតាំងមន្ត្រីមួយរូបជា រដ្ឋទេយ្យករចំណូល ដែលមានភារកិច្ចប្រមូលចំណូលបង់ចូលរតនាគាររាជធានី ខេត្តនិងរក្សាទុកប្រាក់ចំណូលក្នុងកម្រិត ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ជូន។

រតនាគាររាជធានី ខេត្ត ដែលជាគណនេយ្យករសាធារណៈ និងជាគណនេយ្យករមុខការនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងអំពីស្ថានភាពគណនីប្រាក់បញ្ញើនៅរៀងរាល់ខែនីមួយៗដល់ថ្នាក់រដ្ឋបាលទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ខ.១.ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឲ្យប្រមូលសម្រាប់ជាគុណប្រយោជន៍នៃថវិការាជធានី ខេត្ត។ រាជធានី ខេត្ត ត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាននិងត្រូវរួមចំណែកដាក់ចេញនូវវិធានការជាក់ស្តែងសម្រាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវឲ្យអ្នកជាប់ពន្ធបង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា។ ទន្ទឹមនឹងនោះ រាជធានី ខេត្ត ត្រូវចាត់ឲ្យមានមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យ ស្ថិតិ និងកម្រងព័ត៌មានដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារសម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត ដើម្បីជួយដល់មន្ត្រីពន្ធដារក្នុងការប្រមូលចំណូល និងធ្វើជាឯកសារបង្អែកក្នុងការរៀបចំគម្រោងចំណូលពន្ធដារ សម្រាប់ឆ្នាំនីមួយៗ។

### ខ.២.ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឲ្យប្រមូលសម្រាប់ថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារឲ្យអស់មិនត្រូវទុកចំណូលខ្លះនៅដោយឡែក សម្រាប់ចំណាយដោយឡែកក្រៅពីគម្រោងចំណាយប្រចាំឆ្នាំឡើយ។

ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ក៏ត្រូវបង់ចូលថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែរ។ ជៀសវាងទុកចំណូលនោះដោយឡែកសម្រាប់ចំណាយដោយឡែកគ្មានតម្លាភាព។

ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ បើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើឲ្យមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលឲ្យបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា។

### ខ.៣.ចំណូលឧបត្ថម្ភពីថវិកាជាតិ

ចំពោះរាជធានី ខេត្ត ក្រុង ស្រុក ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិកាជាតិ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិកាជាតិនៅក្នុងគម្រោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថាថវិកាជាតិត្រូវតែជាច់ខាតឧបត្ថម្ភតាមចំនួននោះទេ។ ចំណូលឧបត្ថម្ភពីថវិកាជាតិ គឺត្រូវពិនិត្យជូនរាជធានី ខេត្ត ក្រុង ស្រុក ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិកាជាតិ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក។

### ខ.៣.១ ចំណូលឧបត្ថម្ភពីថវិកាជាតិប្រចាំត្រីមាស

ចំពោះចំណូលនេះ រាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ។ នៅដើមត្រីមាសទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភជូនរាជធានី ខេត្ត ក្រុង ស្រុក ដោយមិនបាច់មានការស្នើសុំទេ។ ដោយឡែកសម្រាប់ត្រីមាសទី ២ ទី ៣ និងទី ៤ រាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាព នៅដើមខែ នៃចុងត្រីមាសមុន ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- របាយការណ៍អនុវត្តចំណូល ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគាររាជធានី ខេត្ត
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយ ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័ក និងអាណាត្តិបើកប្រាក់(ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់)

### ខ.៣.២ ចំណូលឧបត្ថម្ភពីថវិការាជធានី

#### ខ.៣.២.១.ចំណូលឧបត្ថម្ភពីថវិការាជធានីជូនខណ្ឌ៖

រាជធានី ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាពី អនុគណនី៦៥១១ (ឧបត្ថម្ភកធន ដល់ ក្រុង ស្រុក ខណ្ឌ)ជូនបណ្តាខណ្ឌប្រចាំត្រីមាសនីមួយៗ ខណ្ឌត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាព មករាជធានីដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- របាយការណ៍អនុវត្តចំណូល ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគាររាជធានី ខេត្ត
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយ ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័កផ្ទេរសិទ្ធិ និងអាណត្តិបើកប្រាក់(ថតចម្លង) ដែលអាណាប័កផ្ទេរសិទ្ធិ បានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់)

#### ខ.៣.២.២.ចំណូលឧបត្ថម្ភពីថវិការាជធានីជូនសង្កាត់៖

រាជធានី ត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទាន ថវិកាពីអនុគណនី ៦៥១២ (ឧបត្ថម្ភកធន ដល់ឃុំ សង្កាត់)ជូនបណ្តាសង្កាត់ផ្អែកលើតួលេខទទួលបានពីការបែងចែកជំនួសពីមូលនិធិឃុំ សង្កាត់។

### ខ.៣.៣. ចំណូលឧបត្ថម្ភពីថវិកាក្រុង

ចំណូលឧបត្ថម្ភពីថវិកាក្រុងជូនសង្កាត់ ក្រុងត្រូវធ្វើអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាពីអនុគណនី ៦៥១២ (ឧបត្ថម្ភកធនដល់ឃុំសង្កាត់)ជូនបណ្តាសង្កាត់ផ្អែកលើតួលេខទទួលបានពីការបែងចែកជំនួសពីមូលនិធិឃុំ សង្កាត់។

### ខ.៣.៤ ចំណូលឧបត្ថម្ភពីថវិកាជាតិសំរាប់វិនិយោគសាធារណៈ

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការផ្ទេសម្រាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈ ទៅក្នុងថវិការាជធានី ខេត្ត ក្រុង ស្រុក ដូច្នេះពេលស្នើសុំគឺរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែម្តង។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

#### ខ.៣.៤.១.ឧបត្ថម្ភសម្រាប់មូលនិធិបដិភាគ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ក្រុង ស្រុក ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគម្រោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅរាជធានី ខេត្ត ក្រុង ស្រុក។

#### ខ.៣.៤.២.ឧបត្ថម្ភវិនិយោគដោយថវិកាជាតិ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ក្រុង ស្រុក ឬប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

### គ.អំពីចំណាយ

ឆ្នាំ២០១៣នេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាថ្នាក់ថវិកាមួយ (ខណ្ឌជាថវិកាផ្នែករបស់រាជធានី) ដូចនេះ ដើម្បីអនុវត្តចំណាយមានប្រសិទ្ធភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការតែងតាំងមន្ត្រីទទួលខុសត្រូវដូចខាងក្រោម៖

- ការចំណាយឥណទានបៀវត្សត្រូវអនុវត្តដោយមានការបង្កើត និងតែងតាំងមន្ត្រីទទួលខុសត្រូវ មួយរូបដោយឡែកហៅថា "ភ្នាក់ងារបើកផ្តល់" ភ្នាក់ងារបើកផ្តល់ត្រូវរៀបចំអាណត្តិបើកប្រាក់ សលាកប័ត្រកត់ត្រាចំណាយថវិកានិងត្រួតពិនិត្យហិរញ្ញវត្ថុ ព្រមទាំងតារាងបៀវត្ស ដែលមានរាយនាមមន្ត្រីរាជការទាំងអស់ដាក់ជូនអភិបាលនៃគណៈអភិបាល ពិនិត្យចុះហត្ថលេខា។
- ការចំណាយថវិកាតាមរយៈរដ្ឋទេយ្យបុរេប្រទាន អភិបាលនៃគណៈអភិបាលត្រូវបង្កើតនិងតែងតាំងមន្ត្រីមួយរូបជា"រដ្ឋទេយ្យករបុរេប្រទាន" ក្នុងការអនុវត្តជាក់ស្តែងកិច្ចការខ្លះត្រូវមានប្រាក់មុនដើម្បីដំណើរការរួចទើបប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការនានារៀបចំអាណត្តិបើកប្រាក់ធ្វើការទូទាត់ជាក្រោយ។
- ក្រោយពីបានតែងតាំងភ្នាក់ងារបើកផ្តល់និងរដ្ឋទេយ្យករបុរេប្រទានរួច ភ្នាក់ងារបើកផ្តល់និងរដ្ឋទេយ្យករបុរេប្រទាន ត្រូវធ្វើលិខិតសុំបើកគណនីប្រាក់បញ្ញើនៅធនាគាររាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវ សេចក្តីសម្រេចតែងតាំងនិងគំរូហត្ថលេខា។
- ចំពោះរដ្ឋបាលសង្កាត់ ការអនុវត្តចំណាយថវិកាត្រូវប្រតិបត្តិទៅតាមលិខិតបទដ្ឋានស្តីពីការអនុវត្តថវិកាឃុំសង្កាត់ជាធរមានដែលបានអនុវត្តកន្លងមក។

#### គ.១.ចំណាយចរន្ត:

ចំណាយចរន្ត រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់ទៅតាមគោលការណ៍ និងនីតិវិធីដូចគ្នានៃចំណាយថវិកាជាតិដែរពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់។ ចំពោះបៀវត្សមូលដ្ឋានប្រាក់កម្រៃបុគ្គលិកអណ្តែត និងភ្នាក់ងារជាប់កិច្ចសន្យាត្រូវអនុវត្តតាមតារាងបើកប្រាក់ដែលចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងបានផ្តល់ទិដ្ឋាការដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈរួច ។ ចំណែកប្រាក់ឧបត្ថម្ភចំពោះ

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២១៤ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានគ្រោងនៅក្នុងអនុគណនី ៦៤៤២ (លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ)

- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរជ្ជទេយ្យបុរេប្រទាន ដែលកំណត់ឡើងដោយដីកាបេស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ពេលដកប្រាក់ពីរតនាគារ រជ្ជទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ)។ចំពោះការចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន សម្រាប់ថវិកាឆ្នាំ ២០១៣នេះ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពិភាក្សាឲ្យបានល្អិតល្អន់ជាមួយប្រធានរតនាគាររាជធានី ខេត្ត និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការកំណត់ទំហំឥណទាន និងចំនួនជុំបង្វិល ដើម្បីធានាឲ្យឥណទានរជ្ជទេយ្យបុរេប្រទានអាចបម្រើបានទាន់ពេលវេលា ទាំងនៅរដ្ឋបាលថ្នាក់រាជធានី ខេត្ត ទាំងនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានអនុវត្តរួចហើយ។

ដោយឡែកការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក យោងតាមមាត្រា៤២ នៃអនុក្រឹត្យលេខ ១៧២អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក អាណាប័កត្រូវធ្វើការសន្យាចំណាយ ដើម្បីអនុវត្តវិធាននៃកិច្ចលទ្ធកម្មសាធារណៈជាធរមាន និងបំពេញកិច្ចជំរះបញ្ជី រួចធ្វើការបោះផ្សាយអាណត្តិ បញ្ជូនទៅរតនាគារខេត្តតាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីត្រួតពិនិត្យថវិកា និងចុះទិដ្ឋាការលើអាណត្តិបើកប្រាក់។

ការត្រួតពិនិត្យថវិកា ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ប្រព្រឹត្តទៅយ៉ាងយូរបំផុតរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានាថា៖

+ ការចំណាយសម្រេចបានតាមគោលបំណង នៃការរៀបចំថវិកាដែលបានអនុម័ត
+ តុល្យភាពពិតប្រាកដក្នុងដំណើរការអនុវត្តថវិកាត្រូវបានថែរក្សាជាប្រចាំ
+ កាតព្វកិច្ចចំណាយត្រូវបានអនុវត្ត
+ កាតព្វកិច្ចបំណុលត្រូវបានរំលោះ
+ វិធានការដោះស្រាយឱនភាពថវិកាត្រូវបានដំណើរការពេលមានឱនភាពថវិកា
+ និយ័តកម្ម ឬការកែតម្រូវថវិកាត្រូវបានបំពេញទៅតាមល័ក្ខខណ្ឌដែលបានកំណត់។

- ចំពោះជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវអនុវត្តចំណាយជំពូកនេះដោយផ្ទាល់ទេ។ នៅពេលមានតម្រូវការចំណាយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលើកគម្រោងឆ្លងការអនុម័តពីក្រុមប្រឹក្សា និងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀតទៅតាមតម្រូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសម្រាប់តម្រូវការប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍គុណប្រយោជន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## គ.២.ចំណាយជាមូលធនៈ

ចំពោះការចំណាយជាមូលធន គឺចែកចេញជាពីរ ៖

### គ.២.១. ចំណាយសំរាប់មូលនិធិបដិភាគៈ

ក្នុងពេលអនុវត្តរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់នូវគម្រោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ។ រតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ ឬផ្ទេរឥណទាននេះ ទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគាររាជធានី ខេត្ត ឬធនាគារ (បើមាន)។

**គ.២.២.ចំណាយវិនិយោគ**

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬហិរញ្ញប្បទានដោយថវិកាជាតិឧបត្ថម្ភក៏ដោយគឺ ត្រូវតែបំពេញបែបបទ និងអនុវត្តឲ្យបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់ឲ្យបានត្រឹមត្រូវតាមការិយបរិច្ឆេទដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា។

## គ.៣.ការកែតម្រូវគម្រោងថវិកា

យោងប្រការ ៤២ នៃច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឲ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីធានាតុល្យភាពថវិកាឡើងវិញ។ នៅក្នុងឆ្នាំថវិកាប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុក ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬ ធ្វើនិយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនានា ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា ។ នៅដំណាច់ឆ្នាំថវិកាអតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ។

ដូច្នេះ នៅត្រីមាសទី ៤ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគម្រោងចំណូលប្រចាំឆ្នាំ។ ប្រសិនបើមានចំណូលលើសពីគម្រោងចំណូលប្រចាំឆ្នាំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក អាចស្នើសុំបន្ថែមលើគម្រោងចំណាយប្រចាំឆ្នាំ សម្រាប់ចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដែលជាចំណាយសម្រាប់វិនិយោគអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ហើយរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលំអិតតាមការដ្ឋាននីមួយៗ។

ចំពោះអតិរេកថវិការបស់រដ្ឋបាលសង្កាត់ឆ្នាំ២០១២ ក្នុងករណីដែលតួលេខជាក់ស្តែងលើសពីគម្រោងដែលបានប៉ាន់ស្មាន សង្កាត់ត្រូវលើកគម្រោងចំណាយបន្ថែមឆ្លងការអនុម័តពីក្រុមប្រឹក្សាដើម្បីអនុវត្ត និងត្រូវបូកសរុបនៅក្នុងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៣ ហើយត្រូវបញ្ជូនទៅបូកបញ្ចូលក្នុងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៣ របស់រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង។

ចំពោះការប្រើប្រាស់អតិរេកនៃថវិកាថ្នាក់ក្រោមជាតិនេះ ដែលកន្លងទៅត្រូវបានបែងចែកឲ្យប្រើប្រាស់តាមច្បាប់សម្រាប់ការអភិវឌ្ឍមូលដ្ឋាន ជាពិសេសវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅត្រីមាសទី៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការណែនាំតាមក្រោយ ម្យ៉ាងដើម្បីជៀសវាងហានិភ័យផ្សេងៗនិយាយជារួម ហើយម្យ៉ាងទៀតដើម្បីអនុវត្តឲ្យបានពេញលេញនូវនិតិវិធីហិរញ្ញវត្ថុជាធរមាននិយាយដោយឡែក។

## គ.៤.ការបង្វែរឥណទាន

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតឲ្យអនុវត្តចាប់ពីចុងត្រីមាសទី២។ ក្នុងករណីមានការចាំបាច់និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ រាជធានី ខេត្ត ក្រុង ស្រុក (ខណ្ឌត្រូវធ្វើសំណើមករាជធានី) ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែង ដែលបានអនុវត្តកន្លងមកនិងគម្រោងប៉ាន់ស្មានចំណាយលំអិតដល់បំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

## ឃ.ការរៀបចំកម្មវិធីនិងរបាយការណ៍ចំណូល ចំណាយ

### ឃ.១.ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគម្រោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលនិងបែងចែកឥណទានចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគាររាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ។ ដោយឡែកសម្រាប់ត្រីមាសទី ២ ទី៣ និងទី៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស គឺជាឯកសារគោល ដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ។

### ឃ.២.ការរៀបចំរបាយការណ៍ចំណូល ចំណាយ

រៀងរាល់ខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍បូកសរុប

ការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃយ៉ាងយូរ១៥ថ្ងៃក្រោយពេលបញ្ចប់ការិយបរិច្ឆេទនីមួយៗ។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឲ្យចំទិសដៅ និងមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិការាជធានី ខេត្ត លេខ ២០៥ សហវ.ថ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះនៅរក្សាសុពលភាពដដែល ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល:</u>**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)
- គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
- គ្រប់សាខាពន្ធដាររាជធានី ខេត្ត
- (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ